សប្តាហ៍ទី 43

សាខេ

សាខេបានឡើងដើមឈើដើម្បីមើលព្រះយេស៊ូ ព្រោះគាត់មានមានកម្ពស់ទាប មិនអាចមើលរំលងហ្វូងមនុស្សបានទេ។ ព្រះយេស៊ូស្រឡាញ់សាខេ យាងទៅផ្ទះគាត់ ហើយបានផ្លាស់ប្តូរចិត្តគំនិតរបស់គាត់។

រឿងក្នុងព្រះគម្ពីរ

សាខេមានមាឧតូចទាប អ៊ីចឹងគាត់ក៏ឡើងដើមឈើមួយដើមដើម្បីមើលព្រះយេស៊ូ។

ព្រះយេស៊ូងើបព្រះភក្ត្រឡើងហៅឈ្មោះគាត់ ហើយយាងទៅផ្ទះរបស់គាត់។

សាខេមានអំណរយ៉ាងខ្លាំង ហើយបានសន្យាថា៖ "ខ្ញុំនឹងចែកទ្រព្យសម្បត្តិចំនួនពាក់កណ្តាលឱ្យដល់អ្នកក្រ ហើយប្រសិនបើខ្ញុំទារពន្ធពីអ្នកណាហួសកម្រិត ខ្ញុំនឹងសងគេវិញ"។

ព្រះយេស៊ូបានជួបគាត់ ហើយចិត្តគំនិតរបស់គាត់ក៏ត្រូវបានផ្លាស់ប្តូរ។

«បុត្រមនុស្សបានមក ដើម្បីស្វែងរក និងសង្គ្រោះមនុស្សដែលវិនាសបាត់បង់» [លូកា១៩៖១០]។



វត្ថុបំណង

- ឯនពីរឿងរបស់សាខេ និងសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ
- ទទួលបានបទពិសោធន៍ក្នុងការប្រើប្រាស់សម្ភារៈផ្សេងៗ និងបង្ហាញម៉ូដស្លឹកឈើតាមរបៀបប្លែកៗគ្នា
- សហការជាមួយមិត្តភក្តិ ដើម្បីបញ្ចប់គម្រោងការងារមួយនេះ
- អរព្រះគុណសម្រាប់ស្នាដៃដែលបានបញ្ចប់ និងបណ្តុះឱ្យមានចិត្តចេះដឹងគុណ។

សម្ភារៈ



ក្រដាសកាតុងពណ៌ត្នោត (សម្រាប់ធ្វើគល់ឈើ)



ក្រដាសពណ៌ (សម្រាប់ធ្វើស្លឹកឈើ)



ថ្នាំពណ៌ទឹក Oil pastels ហ្វឹត ឬខ្មៅដៃពណ៌



កន្ត្រៃ



ការ

របៀបធ្វើសកម្មភាព

1. រៀបចំក្រដាសពណ៌ត្នោតផ្ទាំងធំ ដើម្បីធ្វើជាគល់ឈើ។
2. រៀបចំក្រដាសពណ៌ត្នោតផ្ទាំងធំ ដើម្បីធ្វើជាគល់ឈើ។
3. តុបតែងស្លឹកឈើ ដោយប្រើថ្នាំពណ៌ទឹក ពណ៌ក្រមួន ឬហ្វឹតឱ្យបានស្រស់ស្អាត។
4. បិទស្លឹកឈើទាំងនោះភ្ជាប់ទៅនឹងដើមឈើ។
5. បន្ថែមផ្តាដែលធ្វើដោយមិត្តភក្តិ នៅជុំវិញដើមឈើ។
6. ដើមឈើរបស់យើងមានស្លឹកច្រើន ហើយរួចរាល់!













ការពង្រីកសកម្មភាព

- បង្ហាញម៉ូដស្លឹកឈើប្លែកៗ ដោយប្រើប្រាស់សម្ភារៈផ្សេងៗគ្នា។
- ប្រៀបធៀបស្លឹកឈើរបស់មិត្តភក្តិទាំងពណ៌ និងរូបរាង ហើយកោតសរសើរពីចំណុចពិសេសឯងៗខ្លួន។
- យកស្លឹកឈើមកដាក់ផ្ទុំបញ្ចូលគ្នាថែមទៀត ដើម្បីឱ្យដើមឈើធំរបស់យើងកាន់តែស្រស់ស្អាត។
- តាំងបង្ហាញស្នាដៃដែលធ្វើរួចនៅលើជញ្ជាំង ហើយកោតសរសើរវាទាំងអស់គ្នា។

Tip សម្រាប់គ្រូ

- រៀបចំស្លឹកឈើឱ្យមានទំហំ និងរូបរាងផ្សេងៗគ្នា ដើម្បីឱ្យដើមឈើមើលទៅកាន់តែមានស្លឹកស៊ីបទ្រុប។
- លើកទឹកចិត្តឱ្យកុមារបញ្ចេញគំនិតដោយសេរី ក្នុងការប្រើពណ៌ និងគំរូម៉ូដផ្សេងៗ។
- សរសើរពីការខិតខំប្រឹងប្រែងរបស់កុមារ និងការផ្លាស់ប្តូរចិត្តគំនិតរបស់សាខេ។
- ជួយឱ្យកុមារយល់ថា ព្រះយេស៊ូស្រឡាញ់មនុស្សគ្រប់គ្នា ហើយទ្រង់តែងតែយាងមកជួបយើងជានិច្ច។
- បន្ទាប់ពីធ្វើរួចរាល់ សូមទុកពេលវេលាដើម្បីឱ្យកុមារចែករំលែក៖ "តើកូនៗចូលចិត្តអ្វីជាងគេនៅថ្ងៃនេះ?"។ តស់! យើងមករម្លឹកអាមើលឯងរបស់សាខេទាំងអស់គ្នា។

